ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ០១នាក់ និងករណីជាសះស្បើយ ០៣នាក់
# នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

## ១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖

គិតត្រឹមម៉ោង ០៧:០០ព្រឹក ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **២០០នាក់** (ស្មើនឹង ៨២,៩៩% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះមានស្រី ៤៣នាក់ និងបុរស ១៥៧នាក់
- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **២៤១នាក់** (ស្ត្រី ៤៦នាក់ និងបុរស ១៩៥នាក់។
- អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋ មានចំនួនសរុប **៣៩នាក់**៖
    - នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មានចំនួន ០២នាក់ (ស្ត្រី ០១នាក់ និងបុរស ០១នាក់)
    - នៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញមានចំនួន ៣១នាក់ (ស្ត្រី ០១នាក់ និងបុរស ៣០នាក់)
    - នៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺមានចំនួន ០៦នាក់ ជាបុរស
- អ្នកសម្រាកព្យាបាលនៅបន្ទប់ដោយឡែកក្នុងស្ថានទូតអាមេរិកប្រចាំកម្ពុជា៖ ចំនួន **០២នាក់** ( ស្ត្រីជនជាតិអាមេរិកកាំង **០១នាក់** និងបុរសជនជាតិអាមេរិកកាំង **០១នាក់**)។

## ២. ករណីជាសះស្បើយ៖ បុរសជនជាតិខ្មែរ ០២នាក់ និងបុរសជនជាតិអាមេរិកកាំង ០១នាក់

- បុរសអាយុ ២៥ឆ្នាំ មានអាស័យដ្ឋាននៅភូមិ៣ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- បុរសអាយុ ២៧ឆ្នាំ មានអាស័យដ្ឋាននៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប

បុរសជនជាតិខ្មែរទាំងពីរនាក់ខាងលើ ជាអ្នកធ្វើដំណើរតាមជើងហោះហើរមកពីប្រទេសរុស្ស៊ី បន្តជើងហោះហើរនៅប្រទេសម៉ាឡេស៊ីមកកម្ពុជា ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

- បុរសជនជាតិអាមេរិកកាំង ជាមន្ត្រីការទូតជាន់ខ្ពស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា កាន់វីសាប្រភេទ A មានអាស័យដ្ឋានស្នាក់នៅក្នុងស្ថានទូតអាមេរិកប្រចាំកម្ពុជា រាជធានីភ្នំពេញ។ គាត់បានធ្វើដំណើរពីសហរដ្ឋអាមេរិក បន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូងមកកម្ពុជា ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង ដែលគ្រប់គ្រង និងរាយការណ៍ដោយស្ថានទូតអាមេរិកប្រចាំកម្ពុជា។

**៣. ករណីវិជ្ជមានវីរុសកូវីដ-១៩ថ្មី ៖** បុរសជនជាតិអាមេរិកកាំង ចំនួន ០១នាក់

- បុរសជនជាតិអាមេរិកកាំង ជាមន្ត្រីការទូតជាន់ខ្ពស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា កាន់វីសាប្រភេទ A មានអាស័យដ្ឋានស្នាក់នៅក្នុងស្ថានទូតអាមេរិកប្រចាំកម្ពុជា រាជធានីភ្នំពេញ។ គាត់បានធ្វើដំណើរពីសហរដ្ឋអាមេរិក បន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូងមកកម្ពុជា ដែលលទ្ធផលវិភាគវត្ថុសំណាកលើកទី៣នាថ្ងៃទី១៥នៃការធ្វើចត្តាឡីស័ករបស់គាត់ រាយការណ៍ដោយស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា ទទួលបានលទ្ធផល វិជ្ជមានវីរុសកូវីដ-១៩ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០។ អ្នកជំងឺត្រូវបានដាក់នៅក្នុងបន្ទប់មួយដោយឡែកនៅក្នុងស្ថានទូតអាមេរិកប្រចាំកម្ពុជា ដើម្បីធ្វើការព្យាបាលដោយក្រុមគ្រូពេទ្យអាមេរិកាំងនៃស្ថានទូតនេះ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអង្គារ ១៥កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០

## និន្នាការនៃចំនួនវិជ្ជមានកូវីដ-១៩ សរុបប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

**គិតដល់ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០**

**ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត**

**សរុប ២៤១ ករណី**







មានបុរសចំនួន ០៦នាក់ ជាអ្នកដំណើរមកពីប្រទេសរុស្ស៊ី តាមជើងហោះហើរម៉ាឡេស៊ីបានសម្រាកព្យាបាលនៅ មន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ

ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០

### ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញ បែងចែកតាមសញ្ជាតិ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## Epidemiology and Measures

Confirmed Cases of COVID-19 by date of positive test and acquisition status, 03 August 2020 ( N=241 )




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## Epidemiology and Measures

Confirmed Cases of COVID-19 by date of positive test and acquisition status, 03 August 2020 ( N=241 )




21May-27 Jun- Adjustment measures allowing travel between districts and province and from overseas: detected 19 imported new cases among travelers from overseas

11 July-16 July- Adjustment measures allowing travel between districts and province and from overseas: detected 30 imported new cases among travelers from overseas

20 July-03 August Adjustment measures allowing travel between districts and province and from overseas: detected 70 imported new cases among travelers from overseas

ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

**គិតដល់ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០**

**ចំនួនករណីវិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត**

**សរុប ២៤១ ករណី**




ប្រភព៖ ក្រសួងសុខាភិបាល